វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ប្រកាស/៧៥ ប្រក/ដ.ន.ស/ ០២ កញ្ញា ១៩៩៩

ប្រកាសស្តីពី ការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតិសាងសង់
- តាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១:

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ប្រការ ២:

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ ត្រូវបានបែងចែកជា ៤ ប្រភេទ:

ក- ប្រភេទទី ១ : សហគ្រាស និង ក្រុមហ៊ុនដែលមាន:

ក.១. ស្ថាបត្យករយ៉ាងតិច ៣ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ ។

ក.២ វិស្វករយ៉ាងតិច ៥ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញផ្សេង ៗ យ៉ាងតិច ៥ ឆ្នាំ ។

ក.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ក.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួន សមស្រប ។

ក.៥ បទពិសោធលើការងារសិក្សាគំរោងដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃសិក្សាគំរោងយ៉ាងតិចចំនួន ៨០០,០០០,០០០ រៀល ។

ក.៦ ដើមទុនយ៉ាងតិចចំនួន ២០០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

ខ. ប្រភេទទី ២: ជាសហគ្រាស និង ក្រុមហ៊ុនដែលមាន:

ខ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

ខ.២ វិស្វករយ៉ាងតិច ៤ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញផ្សេង ៗ យ៉ាងតិច ៤ ឆ្នាំ ។

ខ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណងស៊ីវិល ឬ ស្ថាបត្យករ ១ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៦ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួន សមស្រប ។

ខ.៥ បទពិសោធលើការងារសិក្សាគំរោងដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃសិក្សាគំរោងយ៉ាងតិចចំនួន ២០០,០០០,០០០ រៀល ។

ខ.៦ ដើមទុនយ៉ាងតិចចំនួន ៨០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

គ. ប្រភេទទី ៣: ជាសហគ្រាស និងក្រុមហ៊ុនដែលមាន:

គ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៣ ឆ្នាំ ។

គ.២ វិស្វករយ៉ាងតិច ៣ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញផ្សេង ៗ យ៉ាងតិច ៣ ឆ្នាំ ។

គ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណងស៊ីវិល ឬ ស្ថាបត្យករ ១ នាក់ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

គ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួន សមស្រប ។

គ.៥ ដើមទុនយ៉ាងតិចចំនួន ២០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

ឃ. ប្រភេទទី ៤: ជារូបវន្តបុគ្គល

ឃ.១ ស្ថាបត្យករ ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ដោយមានការទទួលស្គាល់ពីរដ្ឋាភិបាល ។

ឃ.២ ស្ថាបត្យករ ដែលមានបទពិសោធការងារក្នុងមុខជំនាញផ្សេង ៗ យ៉ាងតិច ៥ ឆ្នាំ ។

ឃ.៣ ស្ថាបត្យករ ដែលមានបទពិសោធការងារក្នុងមុខជំនាញផ្សេង ៗ យ៉ាងតិច ៣ ឆ្នាំ ។

ឃ.៤ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ឃ.៥ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៣ ឆ្នាំ ។

ឃ.៦ វិស្វករស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និងអ្នកបច្ចេកទេសសំណង់អគារ ឬ សំណង់ស៊ីវិល ។

ឃ.៧ អ្នកបច្ចេកទេសថ្នាក់មធ្យមសំណង់អគារ ឬ សំណង់ស៊ីវិលស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និង វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ។

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ អាចសុំតម្លើងឋានៈរបស់ខ្លួននៅពេលណាដែលសហគ្រាស និង ក្រុមហ៊ុន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ២ នេះ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ប្រការ ៣:

សហគ្រាស និង ក្រុមហ៊ុនសាងសង់ ត្រូវបានបែងចែកជា ៤ ប្រភេទ:

ក. ប្រភេទទី ១: ជាសហគ្រាស និង ក្រុមហ៊ុនដែលមាន:

ក.១.ចំនួនវិស្វករ ២ នាក់ និង ស្ថាបត្យករ ២ នាក់ មានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ១០ ឆ្នាំ នៅក្នុងនោះ វិស្វករ ១នាក់ ទទួលបន្ទុកជានាយកបច្ចេកទេស និង ស្ថាបត្យករ ១ នាក់ជានាយកគំរោង ។

ក.២ វិស្វករយ៉ាងតិច ៦ នាក់ ទទួលបន្ទុកជំនាញផ្សេង ៗ ( អគ្គិសនី មេកានិក ទឹក ភូគព្ភសាស្ត្រឋានលេខា) ។

ក.៣ ដើមទុនយ៉ាងតិចចំនួន ៤០០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

ក.៤ បទពិសោធន៍ការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិចចំនួន ២០,០០០,០០០,០០០ រៀល ។

ខ. ប្រភេទទី ២: ជាសហគ្រាស និង ក្រុមហ៊ុនដែលមាន:

ខ.១.ចំនួនវិស្វករ ១ នាក់ និង ស្ថាបត្យករ ១ នាក់ មានបទពិសោធការងារក្នុងមុខជំនាញយ៉ាងតិច ៨ ឆ្នាំ នៅក្នុងនោះ វិស្វករ មានតួនាទីជានាយកបច្ចេកទេស និង ស្ថាបត្យករជានាយកគំរោងនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.២ វិស្វករយ៉ាងតិច ៤ នាក់ ទទួលបន្ទុកជំនាញផ្សេង ៗ ( អគ្គិសនី មេកានិក ទឹក ភូគព្ភសាស្ត្រឋានលេខា) ។

ខ.៣ ដើមទុនយ៉ាងតិចចំនួន ១២០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

ខ.៤ បទពិសោធន៍ការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិចចំនួន ៤,០០០,០០០,០០០ រៀល ។

គ. ប្រភេទទី ៣: ជាសហគ្រាស និង ក្រុមហ៊ុនដែលមាន:

គ.១.ចំនួនវិស្វករ ១ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេស នៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

គ.២ វិស្វករ ២ នាក់ ទទួលបន្ទុកជំនាញផ្សេង ៗ ។

គ.៣ ដើមទុនយ៉ាងតិចចំនួន ២០,០០០,០០០ រៀល ដែលទទួលស្គាល់ដោយធនាគារស្របច្បាប់ ។

ឃ. ប្រភេទទី ៤: ជាក្រុមជាងសំណង់:

ឃ.១. មេជាងដែលមានស្នារដៃ និង បទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ ឆ្នាំ។

ឃ.២ ជាងសំណង់មួយចំនួន សមស្រប ។

សហគ្រាស និង ក្រុមហ៊ុនសាងសង់ អាចសុំតម្លើងថានៈប្រភេទរបស់ខ្លួននៅពេលណាដែលសហគ្រាស និង ក្រុមហ៊ុន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ៣ នេះ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

ប្រការ ៤:

អាជ្ញាធរដែលមានសមត្ថកិច្ចបើក បិទ ផ្អាក តាមដាន និង ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោង ប្លង់ និង សាងសង់ មាន:

១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- ចេញលិខិតអនុញ្ញាតិប្រកបអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។
- ប្រកាសបិទ ផ្អាកអាជីវកម្មរបស់ សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។
- តាមដាន ត្រួតពិនិត្យគ្រប់សកម្មភាពអាជីវកម្មរបស់ សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។

២. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- ទទួលបន្ទុកសំរបសំរួល ដើម្បីលើកសំណើរជូនក្រសួងធ្វើសេចក្តីសំរេចក្នុងការចេញលិខិតអនុញ្ញាត បើក បិទ ផ្អាកការប្រកបអាជីវកម្ម គំរោងប្លង់ និង សាងសង់របស់ សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។
- តាមដាន ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់ សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ នៅក្នុងមូលដ្ឋានរបស់ខ្លួន និង រាយការណ៍ជូនក្រសួង ដើម្បីពិនិត្យដោះស្រាយ ។

ប្រការ ៥:

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ដែលមានបំណងធ្វើអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្ម នៅក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

រូបវន្តបុគ្គល (ឃ.៦-ឃ.៧) និងក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំ ប្រកបអាជីវកម្ម នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង។

ប្រការ ៦:

ចំពោះ:

១. សហគ្រាស និង ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតិពីស្ថាប័នផ្សេង ៗ កន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតិថ្មីពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

២. រូបវន្តបុគ្គល (ឃ.៦-ឃ.៧) និងក្រុមជាងសំណង់ ដែលមានលិខិតអនុញ្ញាតិពីស្ថាប័នផ្សេង ៗ កន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតិថ្មីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង។

ប្រការ ៧:

ទម្រង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និងសាងសង់ ត្រូវមានលក្ខខណ្ឌដូចតទៅ:

១- ប្រធានសហគ្រាស និង ក្រុមហ៊ុន ត្រូវមានសញ្ជាតិខ្មែរ ។

២. ប្រធានសហគ្រាស និង ក្រុមហ៊ុន ត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

៣. នាយកបច្ចេកទេសនៃ ប្រធានសហគ្រាស និង ក្រុមហ៊ុន ត្រូវមានសញ្ជាតិខ្មែរ ។

៤. សំណុំឯកសារដែលត្រូវបំពេញរួមមាន:

- ពាក្យសុំប្រកបអាជីវកម្ម ៤ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់ប្រធាន សហគ្រាស និង ក្រុមហ៊ុនដោយមានបិទរូបថតទំហំ ៤ x ៦ ៤ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណរបស់ ប្រធានសហគ្រាស និង ក្រុមហ៊ុនដែលមានធ្វើនីត្យានុកូលកម្ម នៅសាលាខេត្ត-ក្រុង ២ ច្បាប់
- លិខិតថ្កោលទោសរបស់ ប្រធានសហគ្រាស និង ក្រុមហ៊ុន (ច្បាប់ដើម) ១ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេស ដោយមានបិទរូបថតទំហំ ៤ x ៦ ៤ ច្បាប់
- លក្ខន្តិកៈរបស់ សហគ្រាស និង ក្រុមហ៊ុន ៤ ច្បាប់
- កិច្ចសន្យាការងាររវាង សហគ្រាស និង ក្រុមហ៊ុន នឹងអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតិប្រកបអាជីវកម្ម ៤ ច្បាប់
- កិច្ចសន្យាការងាររវាង សហគ្រាស និង ក្រុមហ៊ុន នឹងវិស្វករដែលជានាយកបច្ចេកទេស ៤ ច្បាប់

- ច្បាប់ចម្លងសញ្ញាបត្ររបស់អ្នកបច្ចេកទេសដែលមាន ធ្វើទីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៤ ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និង អង្គការលេខរបស់ សហគ្រាស និង ក្រុមហ៊ុន ៤ ច្បាប់
- ឯកសារស្នាមដៃ ២ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខាសិក្សាគំរោងប្លង់ ( សំរាប់ សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់) ៤ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខាសិក្សាគំរោងប្លង់ ( សំរាប់ សហគ្រាស និង ក្រុមហ៊ុនសាងសង់) ២ ច្បាប់
- ឯកសារធនាគារ ៤ ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ( ច្បាប់ដើម) ១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ១ ច្បាប់

ប្រការ ៨:

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលមានបំណងធ្វើអាជីវកម្មសិក្សាគំរោងប្លង់ ឬ ផ្តល់យោបល់ពិគ្រោះបច្ចេកទេស និង សាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមកចុះបញ្ជីនៅក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលកំពុងប្រកបអាជីវកម្មសិក្សាគំរោងប្លង់ ឬ ផ្តល់យោបល់ពិគ្រោះបច្ចេកទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតិពីស្ថាប័នផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដែរ ។

ប្រការ ៩:

រាល់ការចុះបញ្ជី ការចេញលិខិតអនុញ្ញាតិ សហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់រូបវន្តបុគ្គល និង ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេង ៗ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១០:

លិខិតអនុញ្ញាតិប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ មានសុពលភាពរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតិ ។

រយៈពេល ៣០ ថ្ងៃមុនផុតកំណត់សុពលភាព សហគ្រាស និង ក្រុមហ៊ុនធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតិសារជាថ្មី មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃ លិខិតអនុញ្ញាតិប្រកបអាជីវកម្ម សហគ្រាស និង ក្រុមហ៊ុន ត្រូវធ្វើពាក្យសុំមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតិចាស់ និង បង្កាន់ដៃបង់ពន្ធអាករថ្មី ។

ក្នុងករណីសុំតម្លើងថានៈប្រភេទ សហគ្រាស និង ក្រុមហ៊ុន ត្រូវធ្វើពាក្យសុំមក ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដើម្បីពិនិត្យសំរេច។

សហគ្រាស និង ក្រុមហ៊ុន ត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់រាល់ដំណាច់ឆ្នាំនីមួយ ៗ ។

ប្រការ ១១:

ត្រូវប្រកាសផ្អាក ឬ បិទចំពោះសហគ្រាស ឬ ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងឡាយណាដែលប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់ដោយគ្មានលិខិតអនុញ្ញាតិពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ប្រការ ១២:

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកសំណង់ អគ្គនាយករៀបចំដែនដី និង នគរូបនីយកម្ម អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ អធិការ និង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ១៣:

ប្រកាសនេះ មានអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។